វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី ២៥ ខែមករា ២០១៩**

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺ៖

- ក្រសួងពាណិជ្ជកម្មរបស់កម្ពុជាកាត់បន្ថយកម្រៃ និងបែបបទនៃការនាំចេញ ក្នុងគោលបំណងគាំទ្រដល់ក្រុមហ៊ុននាំចេញអង្ករ
- រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុប្រទេសសិង្ហបុរីកំណត់វិស័យអាទិភាពសម្រាប់ថវិកាឆ្នាំ២០១៩
- ផលិតផលឧស្សាហកម្មរបស់ អាមេរិកមានកើនឡើងលើសការរំពឹងទុក

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗ នៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារ បណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះ មានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តន៍នៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ក្រសួងពាណិជ្ជកម្មរបស់កម្ពុជាកាត់បន្ថយកម្រៃ និងបែបបទនៃការនាំចេញ ក្នុងគោលបំណងគាំទ្រដល់ក្រុមហ៊ុននាំចេញអង្ករ

រដ្ឋាភិបាលកម្ពុជាបានរៀបចំវិធានការមួយចំនួនដើម្បីបង្កើនសមត្ថភាពប្រកួតប្រជែងការនាំចេញ ដើម្បីទូទាត់ការចំណាយក្នុងវិស័យអង្ករ បន្ទាប់ពីការសម្រេចចិត្តរបស់សហភាពអឺរ៉ុបដែលកំណត់ដាក់ពន្ធនាំចូលលើអង្ករដែលនាំមកពីប្រទេសកម្ពុជា។

សរុបមក វិធានការដែលក្រសួងពាណិជ្ជកម្មបានគ្រោងទុក នឹងជួយដល់ក្រុមហ៊ុននាំចេញអង្ករកម្ពុជា គិតជាទឹកប្រាក់មានចំនួន ៦០លានដុល្លារអាមេរិកក្នុងមួយឆ្នាំ (ដែលជាលទ្ធផល គឺស្មើនឹងបរិមាណដូចគ្នាទៅនឹងការបាត់បង់ចំណូលរដ្ឋ)។ វិធានការទាំងនេះរួមមាន៖ ការលុបចោលនូវលក្ខខណ្ឌនៃការដាក់ពាក្យសុំវិញ្ញាបនបត្របញ្ជាក់ពីប្រភពដើម (ដែលជួយដល់អ្នកនាំចេញ គិតជាទឹកប្រាក់ស្មើនឹង ១០លានដុល្លារអាមេរិក) ការបន្ធូរបន្ថយតម្រូវការត្រួតពិនិត្យមួយចំនួន (គិតជាទឹកប្រាក់ស្មើនឹង ៣០លានដុល្លារអាមេរិក) និងការសម្រេចចិត្តក្នុងឆ្នាំ២០១៧ ក្នុងការលុបចោលកម្រៃសម្រាប់គ្រប់គ្រងការនាំចេញ (គិតជាទឹកប្រាក់ស្មើនឹង ២០លានដុល្លារអាមេរិក)។

ការខាតបង់ប្រាក់ចំណូលរបស់ក្រសួងពាណិជ្ជកម្មនេះ គឺស្មើប្រមាណ ៧៣% នៃចំណូលរបស់ក្រសួងពាណិជ្ជកម្ម នៅក្នុងឆ្នាំ២០១៨ (គិតជាទឹកប្រាក់ស្មើនឹង ៨២លានដុល្លារអាមេរិក)។ ផែនការ និងការចំណាយនេះ ត្រូវបានបញ្ជាក់ដោយមន្ត្រីជាន់ខ្ពស់របស់ក្រសួងនៅក្នុងសន្និសីទកាសែតមួយកាលពីសប្តាហ៍មុន។

### តារាងប្រចាំសប្តាហ៍៖ ចំណូលសារពើពន្ធលើពាណិជ្ជកម្មអន្តរជាតិ

ចំណូលសារពើពន្ធរបស់ប្រទេសកម្ពុជាពីពាណិជ្ជកម្មអន្តរជាតិ បានកើនឡើងរហូតដល់ ៥៨៥,២ ប៊ីលានរៀលនៅក្នុងត្រីមាសទី

៣ ឆ្នាំ២០១៨ ដែលកើនឡើងប្រមាណ ២៣% ធៀបទៅនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៧។ កំណើននេះនាំមុខដោយពន្ធនាំចូលដែលបានកើនដល់ ៥៧២,៧ ប៊ីលានរៀល (កើនឡើង ២៣,៨%)។ ទន្ទឹមនឹងនេះ ពន្ធលើការនាំចេញបានធ្លាក់ចុះ ៤% ចំណែកពន្ធលើការនាំចេញផ្សេងទៀតបានធ្លាក់ចុះ១០%ធៀបនឹងត្រីមាសទី៣ ឆ្នាំ២០១៧។

**ចំណូលសារពើពន្ធលើពាណិជ្ជកម្មអន្តរជាតិ**




ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២០១៨

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុប្រទេសសិង្ហបុរី កំណត់វិស័យអាទិភាពសម្រាប់ថវិកាឆ្នាំ២០១៩

លោក Heng Swee Keat រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុនៃប្រទេសសឹង្ហបុរី បានដាក់ចេញនូវចក្ខុវិស័យរបស់លោក សម្រាប់ថវិកាឆ្នាំ២០១៩ នៅក្នុងសន្ទរកថាមួយនៅសប្តាហ៍នេះ។ គម្រោងថវិកានេះ ត្រូវបានរំពឹងថានឹងចាប់ផ្តើមនៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៩ ដែលផ្តល់អាទិភាពទៅលើវិស័យអប់រំ សុខាភិបាល និង សន្តិសុខ។

ក្រៅពីវិស័យអាទិភាពទាំងនេះ លោកបានគូសបញ្ជាក់ផងដែរអំពីកម្មវិធីជាក់លាក់មួយចំនួន ដែលនឹងទទួលបាននូវផែនការលម្អិតបន្ថែមទៀត រួមមានគម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធខ្នាតធំ ដូចជា៖ ផ្លូវរថភ្លើងក្រោមដី អាកាសយានដ្ឋាន និងកម្មវិធីថែទាំជនចាស់ជរារបស់សឹង្ហបុរី។ លោកបានបន្ថែមទៀតថា កត្តាអាទិភាពចំបងមួយទៀត គឺការរក្សាស្ថិរភាពសេដ្ឋកិច្ចសឹង្ហបុរី ខណៈពេលដែលភាពមិនច្បាស់លាស់នៃសេដ្ឋកិច្ចពិភពលោក មានការកើនឡើង។

## សេដ្ឋកិច្ចសហរដ្ឋអាមេរិក និងទុនបម្រុងសហព័ន្ធ

### ផលិតផលឧស្សាហកម្មរបស់អាមេរិក មានកើនឡើងលើសការរំពឹងទុក

ផលិតកម្មឧស្សាហកម្មបានកើនឡើង ០,៣%នៅក្នុងខែធ្នូ ដែលជាកំណើនធ្លាក់ចុះបើធៀបទៅនឹងខែវិច្ឆិកា ដែលមានកំណើន ០,៤%។ ទោះបីជាយ៉ាងណាក៏ដោយ ទិន្នន័យផលិតផលនេះលើសពីការរំពឹងទុករបស់សេដ្ឋវិទូ ដែលជាហេតុនាំអោយប្រាក់ដុល្លារអាមេរិកឡើងថ្លៃ។

កំណើននេះនាំមុខដោយ អនុវិស័យកមន្តសាល ១,១% និងធនធានរ៉ែ ១,៥%។ ការប្រើប្រាស់ទឹកភ្លើងបានធ្លាក់ចុះ ៦,៣% ដោយសារតែអាកាសធាតុមានសភាពក្តៅជាងធម្មតា។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្តាហ៍ខាងមុខនេះរួមមាន៖ អតិផរណារបស់កូរ៉េខាងត្បូង និកម្មភាពនៅជប៉ុន និងស្ថិតិសេដ្ឋកិច្ចសំខាន់ៗរបស់ប្រទេសវៀតណាម។

ខាងក្រោមគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុម FACT នឹងបន្តតាមដាននៅសប្តាហ៍ក្រោយ៖

ថ្ងៃចន្ទ ទី២៨ ខែមករា

- ប្រាក់ចំណេញផ្នែកឧស្សាហកម្មនៅចិន ខែធ្នូ
- របាយការណ៍គោលនយោបាយរូបិយវត្ថុរបស់ធនាគាជប៉ុន
- អត្រាកំណើនប្រាក់កម្ចីនៅតំបន់អឺរ៉ុប ខែធ្នូ
- តុល្យភាពនៃជញ្ជីងពាណិជ្ជកម្មរបស់ហុងកុង ខែធ្នូ
- ការវិនិយោគផ្ទាល់ពីបរទេស ខែមករា

ថ្ងៃអង្គារ ទី២៩ ខែមករា

- តុល្យភាព ពាណិជ្ជកម្មរបស់វៀតណាម ខែមករា
- ផលិតផលឧស្សាហកម្មរបស់វៀតណាម ខែមករា
- ទិន្នន័យលក់រាយរបស់វៀតណាម ខែមករា
- ចំនួនភ្ញៀវទេសចរណ៍នៅវៀតណាម ខែមករា
- ផលិតផលឧស្សាហកម្មនៅប្រទេសថៃ ខែធ្នូ

<u>ថ្ងៃពុធ ទី៣០ ខែមករា</u>

- ទំនុកចិត្តលើការវិនិយោគនៅកូរ៉េខាងត្បូង ខែមករា
- សន្ទស្សន៍តម្លៃសម្រាប់អ្នកផលិតនៅហ្វីលីពីន ខែធ្នូ
- ទិន្នន័យលក់រាយរបស់ជប៉ុន ខែធ្នូ
- តុល្យភាព ពាណិជ្ជកម្មរបស់ម៉ាឡេស៊ី ខែធ្នូ
- ការវិនិយោគផ្ទាល់ពីបរទេសនៅឥណ្ឌូនេស៊ី សម្រាប់ត្រីមាសទី៤ ឆ្នាំ២០១៨

<u>ថ្ងៃព្រហស្បតិ៍ ទី៣១ ខែមករា</u>

- សេចក្តីសម្រេចស្តីពីអត្រាការប្រាក់របស់រដ្ឋសហព័ន្ធនៅអាមេរិក
- ផលិតផលឧស្សាហកម្មរបស់កូរ៉េខាងត្បូង ខែធ្នូ
- និកម្មភាពនៅសឹង្ហបុរី សម្រាប់ត្រីមាសទី៤ ឆ្នាំ២០១៨
- ទិន្នន័យលក់រាយរបស់ប្រទេសថៃ ខែវិច្ឆិកា

<u>ថ្ងៃសុក្រ ទី០១ ខែកុម្ភៈ</u>

- អត្រាអតិផរណានៅកូរ៉េខាងត្បូង ខែមករា
- និកម្មភាពនៅជប៉ុន ខែធ្នូ
- តុល្យភាព ពាណិជ្ជកម្មនៅកូរ៉េខាងត្បូង ខែមករា
- អត្រាអតិផរណានៅប្រទេសថៃ ខែមករា
- អត្រាអតិផរណានៅឥណ្ឌូនេស៊ី ខែមករា